**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៦២៧៤

ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៩

លេខ: 663 អ.យ.ណ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ:សំណុំរឿងព្រហ្មទណ្ឌលេខ ៦២៧៤ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ:ពាក្យបណ្តឹង ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០១៩ របស់ដើមបណ្តឹងឈ្មោះ [redacted] ស្រ៊ីអ៊ុយ ភេទប្រុស កើតឆ្នាំ ១៩៦០ ,២-ឈ្មោះ [redacted] គុង ភេទប្រុស កើតឆ្នាំ ១៩៥៦ ,៣-ឈ្មោះ [redacted] វ៉ាន់យូ ភេទប្រុស កើតឆ្នាំ ១៩៥៤ ,៤-ឈ្មោះ [redacted] អេង ភេទស្រី កើតឆ្នាំ ១៩៥៧ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានថា:

១-នាមត្រកូល-នាមខ្លួន: [redacted] វចនា ភេទ ប្រុស អាយុ ៣៩ ឆ្នាំ , ជនជាតិខ្មែរ ,កាន់សាសនាព្រះពុទ្ធ ,ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង មានទីលំនៅសព្វថ្ងៃនៅ [redacted] ខេត្តព្រៃវែង , មុខរបរមន្ត្រីនគរបាលជាតិ,ប្រពន្ធឈ្មោះ [redacted] "រស់" មានកូន ០៤ នាក់ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ទោសពីមុនគ្មាន ជានីតិជន ។ (ក្រៅឃុំ)

២-នាមត្រកូល-នាមខ្លួន: [redacted] សារន់ ភេទ ប្រុស អាយុ ៥១ ឆ្នាំ , ជនជាតិខ្មែរ ,កាន់សាសនាព្រះពុទ្ធ ,ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង មានទីលំនៅសព្វថ្ងៃនៅ [redacted] ខេត្តព្រៃវែង , មុខរបរប្រធានការិយាល័យ ,ប្រពន្ធឈ្មោះ [redacted] "រស់" មានកូន ០៣ នាក់ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ទោសពីមុនគ្មាន ជានីតិជន ។ (ក្រៅឃុំ)

៣-នាមត្រកូល-នាមខ្លួន: [redacted] សុខុម ភេទ ប្រុស អាយុ ៥៤ ឆ្នាំ , ជនជាតិខ្មែរ ,កាន់សាសនាព្រះពុទ្ធ ,ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង មានទីលំនៅសព្វថ្ងៃនៅ [redacted] ខេត្តព្រៃវែង , មុខរបរមន្ត្រីរាជការ ,ប្រពន្ធឈ្មោះ [redacted] "រស់" មានកូន ០២ នាក់ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ទោសពីមុនគ្មាន ជានីតិជន ។ (ក្រៅឃុំ)

៤-នាមត្រកូល-នាមខ្លួន: [redacted] សុវណ្ណ ភេទ ប្រុស អាយុ ២៩ ឆ្នាំ , ជនជាតិខ្មែរ ,កាន់សាសនាព្រះពុទ្ធ ,ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង មានទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ខេត្តព្រៃវែង , ប្រពន្ធឈ្មោះ [redacted] "រស់" មានកូន ០២ នាក់ ឪពុកឈ្មោះ [redacted] , ម្តាយឈ្មោះ [redacted] ជានីតិជន ។ (ក្រៅឃុំ)



Scanned with CamScanner

ប្រព្រឹត្តអំពើដូចតទៅ៖ កាលពីថ្ងៃ ២៤ ខែ មេសា ឆ្នាំ ២០១៧ និង ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៨ ឈ្មោះ [redacted] រចនា ,ឈ្មោះ [redacted] សារន់ ,ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ បានចុះកិច្ចព្រមព្រៀង-ទិញលក់ដីជាមួយដើមបណ្តឹងឈ្មោះ [redacted] ស្រីអ៊ុយ ,ឈ្មោះ [redacted] គុង [redacted] វ៉ាន់យូ និងឈ្មោះ [redacted] អេង លើផ្ទៃដីសរុបចំនួន ៤១០,៤៦ ហិចតា (បួនរយដប់ក្បៀសសែសិបប្រាំមួយហិចតា) ដែលមានទីតាំងទី១ មានទំហំសរុប ២៣១,៤១ ហិចតា (ពីររយសាមសិបមួយក្បៀសសែសិបមួយហិចតា) មានទីតាំងស្ថិតនៅភូមិ [redacted] ខេត្តព្រៃវែង និងទីតាំងទី២ មានទំហំ ១៧៩,០៥ ហិចតា (មួយរយចិតសិបប្រាំបួនក្បៀសសូន្យប្រាំហិចតា) មានទីតាំងស្ថិតនៅភូមិព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង តាមតម្លៃដែលបានឯកភាពគ្នាដូចនៅក្នុងកិច្ចព្រមព្រៀង ។ ចាប់តាំងពីថ្ងៃចុះកិច្ចព្រមព្រៀងទិញលក់ដីលើកទី១ រហូតមកដល់ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៨ ភាគីអ្នកលក់ទាំងបួននាក់ដែលមានឈ្មោះ [redacted] រចនា , [redacted] សុខុម [redacted] សារន់ និងឈ្មោះ [redacted] សុវណ្ណ បានទទួលប្រាក់ជាបន្តបន្ទាប់ពីភាគីអ្នកទិញ ដែលមានឈ្មោះ [redacted] ស្រីអ៊ុយ , [redacted] គុង , [redacted] វ៉ាន់យូ និងឈ្មោះ [redacted] លេង សរុបចំនួន ២,០៣១,៣៨២ $ (ពីរលានបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរដុល្លារអាមេរិក) រួចហើយតែភាគីអ្នកលក់ពុំមានដីប្រគល់អោយភាគីអ្នកទិញឡើយ ។

-អំពើខាងលើជាបទល្មើស ៖ ឆបោក ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង , កាលពីថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៧៧និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញៈ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☑ ដាក់ស្ថិតក្រោមការពិនិត្យ[1] ៖

១-ឈ្មោះ [redacted] រចនា ភេទ ប្រុស អាយុ ៣៩ ឆ្នាំ ។ (ក្រៅឃុំ)

២-ឈ្មោះ [redacted] សារន់ ភេទ ប្រុស អាយុ ៥១ ឆ្នាំ ។ (ក្រៅឃុំ)

៣-ឈ្មោះ [redacted] សុខុម ភេទ ប្រុស អាយុ ៥៤ ឆ្នាំ ។ (ក្រៅឃុំ)

៤-ឈ្មោះ [redacted] សុវណ្ណ ភេទ ប្រុស អាយុ ២៩ ឆ្នាំ ។ (ក្រៅឃុំ)

ពីបទ៖ ឆបោក ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិ ព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង , កាលពីថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៧ បទ ល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៧៧និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[2] ..........................................

☑ ដាក់ឱ្យស្ថិតនៅការឃុំខ្លួនបណ្តោះអាសន្ន ៖

១-ឈ្មោះ [redacted] រចនា ភេទ ប្រុស អាយុ ៣៩ ឆ្នាំ ។ (ក្រៅឃុំ)

២-ឈ្មោះ [redacted] សារន់ ភេទ ប្រុស អាយុ ៥១ ឆ្នាំ ។ (ក្រៅឃុំ)

៣-ឈ្មោះ [redacted] សុខុម ភេទ ប្រុស អាយុ ៥៤ ឆ្នាំ ។ (ក្រៅឃុំ)

៤-ឈ្មោះ [redacted] សុវណ្ណ ភេទ ប្រុស អាយុ ២៩ ឆ្នាំ ។ (ក្រៅឃុំ)

ថ្ងៃ ចន្ទ ២ រោច ខែ មាឃ ឆ្នាំ កុរឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០

ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញា

[redacted]

[1]ឈ្មោះជនត្រូវចោទ

[2]កាតព្វកិច្ចណាមួយដែលបានចែងក្នុងមាត្រា ២២៣



Scanned with CamScanner